**ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា**

**ការិយាល័យ វាយតម្លៃ៖ បន្ទប់លេខ ២១៤**

440 NORTH BROAD STREET
PHILADELPHIA, PA 19130

**លក្ខណ:ពិសេស និង ការជួយសម្រួល នៃការប្រឡង Keystone/PSSA សម្រាប់ ឆ្នាំ ២០១៩-២០២០**

- នៅពេលប្រឡង សិស្សានុសិស្ស*ទាំងអស់*មានការជ្រើសរើសខ្លះ ដូចជាការប្រើពេលវាលាយូរ និង អានឮៗ គ្រប់ផ្នែកទាំងអស់ នៃវិញ្ញាសា គណិតវិទ្យា វិទ្យាសាស្រ្ត ពិជគណិត១ និង ជីវវិទ្យា និងនៅផ្នែកខ្លះ នៃអក្សរសិល្ប៍អង់គ្លេស ។ល។
- ការជ្រើសរើសដែលមានសម្រាប់សិស្ស*ទាំងអស់* ហៅថា «test features (លក្ខណៈនៃការប្រឡង »
- ការជ្រើសរើសដែលមានសម្រាប់ សិស្សពិការ សិស្ស EL និងសិស្សដែលមាន 504 Plan ដែល*ត្រូវការ* ដើម្បីឲ្យពួកគេអាចចូលរួមក្នុងការវាយតម្លៃ ហៅថា «ការជួយសម្រួល»។ ហេតុដូច្នេះ ការជួយសម្រួល គឺជាការអនុវត្តន៍ដែលផ្តល់ឲ្យមានសមភាពសិស្សានុសិស្សទាំងអស់ ក្នុងការប្រឡងគ្រប់ផ្នែកនៃវិញ្ញាសា។
- ការជួយសម្រួល បានត្រូវចែកចេញជា ៤ ផ្នែក៖ ការបង្ហាញ ការឆ្លើយតប ការរៀបចំ និង ពេលវេលា (Presentation, Response, Setting, and Timing)។
- ការជួយសម្រួល ទាំងអស់ ដែលមានសម្រាប់ការប្រឡង ឃីស្តូន (Keystone  ក៏មានសម្រាប់ការប្រឡង PSSA ដែរ។
- **គឺជាការសំខាន់ ក្នុងការកត់សម្គាល់ថា ការជួយសម្រួលខ្លះ គឺសម្រាប់តែការពន្យល់ណែនាំ ប្រហែលជាមិនអាចប្រើសម្រាប់ការប្រឡងទូទៅបានទេ។**
- ការជួយសម្រួល ត្រូវតែស្របទៅតាមសេចក្តីត្រូវការរបស់សិស្ស សិស្សត្រូវតែសុខចិត្តទទួលការជួយសម្រួលទាំងនោះ ហើយសិស្សត្រូវតែចូលរួមក្នុងការជ្រើសរើសរបស់ពួកគេ (សូមមើល«ព័ត៌មានជំនួយបន្ថែម» នៅក្នុងសេចក្តីណែនាំអំពីការជួយសម្រួល សម្រាប់ការប្រឡង PSSA និង ឃីស្តូន ឆ្នាំ ២០២០* ។
- ការអនុវត្តន៍ដែលល្អបំផុតក្នុងការជ្រើសរើស ការជួយសម្រួល សម្រាប់ការប្រឡង គឺត្រូវប្រើ ការជួយសម្រួល ដែលជាទម្លាប់ធ្លាប់ជួយដល់សិស្ស មុនពេលប្រឡង ហើយបានកត់ត្រាទុកពីការប្រើដែលមានប្រសិទ្ធភាព។ វាមិនមែនជាការអនុវត្តន៍ដ៏ល្អនោះទេ ចំពោះការផ្តល់ ការជួយសម្រួលក្នុងពេលប្រឡង ដែលតាមធម្មតាសិស្សមិនដែលធ្លាប់បានទទួល។

**ការជួយសម្រួល មានសម្រាប់តែសិស្សានុសិស្សដែលត្រូវការរៀនភាសាអង់គ្លេស (ELs**

មាន ការជួយសម្រួល*ដោយស្ម័គ្រចិត្ត*បីដោយឡែក ដែលគេអនុញ្ញាតឲ្យសម្រាប់តែសិស្ស ELs៖

- ១  វចនានុក្រមដែលបកប្រែមួយពាក្យៗ ដែលគ្មាន និយមន័យ គ្មានរូបភាព ឬ ការតភ្ជាប់ទៅអ៊ិនធ័រណិត... អនុញ្ញាតឲ្យប្រើក្នុងពេលប្រឡង ឃីស្តូន ផ្នែក ពិជគណិត១ និង ជីវវិទ្យា និង ការប្រឡង PSSAs ផ្នែក គណិតវិទ្យា និង វិទ្យាសាស្រ្ត **តែប៉ុណ្ណោះ** (មានសម្រាប់សិស្ស ELs **ទាំងអស់** ដោយមិនគិតពីចំនួនឆ្នាំដែលពួកគេបានរស់នៅក្នុងប្រទេសនេះ

- ២  គេអនុញ្ញាតឲ្យមាន អ្នកបកប្រែភាសាដែលមានសមត្ថភាព/បកពីអត្ថបទ**... ក្នុងពេលប្រឡង ឃីស្តូន ផ្នែក ពិជគណិត១ និង ជីវវិទ្យា និង ការប្រឡង PSSAs ផ្នែក គណិតវិទ្យា និង វិទ្យាសាស្រ្ត និង ការពន្យល់ពីការសរសេរ (TDA  អំពីអក្សរសិល្ប៍អង់គ្លេស ក្នុងការប្រឡង PSSA ។ (មានសម្រាប់សិស្ស ELs ដែលរៀននៅសាលាក្នុងសហរដ្ឋ តិចជាង ៣ ឆ្នាំ **តែប៉ុណ្ណោះ**

- ៣  ការប្រឡងជាភាសា អេស្ប៉ាញ៉ុល/អង់គ្លេស និង កូនសៀវភៅសម្រាប់សរសេរចម្លើយ... អនុញ្ញាតឲ្យប្រើក្នុងពេលប្រឡង ឃីស្តូន ផ្នែក ពិជគណិត១ និង ជីវវិទ្យា និង ការប្រឡង PSSAs ផ្នែក គណិតវិទ្យា និង វិទ្យាសាស្រ្ត (មានសម្រាប់សិស្ស ELs ដែលរៀននៅសាលាក្នុងសហរដ្ឋ តិចជាង ៣ ឆ្នាំ **តែប៉ុណ្ណោះ**

**កំណត់សម្គាល់៖** ការជួយសម្រួល សម្រាប់សិស្ស EL ទាំងបីខាងលើនេះ **គ្មាន**សម្រាប់សិស្សានុសិស្សដែលបានចេញពីកម្មវិធីនោះទេ។

*** ដើម្បីជ្រាបព័ត៌មានបន្ថែមអំពី លក្ខណៈពិសេស និង ការជួយសម្រួល សូមប្រើបណ្តាញតភ្ជាប់ខាងក្រោមនេះ ហើយមើលក្នុងជំពូកនៃ ការជួយសម្រួល សម្រាប់ការប្រឡង៖**

https://www.education.pa.gov/K-12/Assessment%20and%20Accountability/PSSA/Pages/TestingInformation.aspx

** សម្រាប់តួនាទីរបស់ អ្នកបកប្រែភាសា សូមប្រើបណ្តាញតភ្ជាប់ខាងលើនេះ ហើយបន្ទាប់មកចុចលើពាក្យ 2020 Accommodations Guidelines for ELs ។